# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ ០១.កយ.សណន-២០០៦

# សេចក្តីណែនាំរួម

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល

**<u>សូមជម្រាបមក</u>**

**លោក លោកស្រី ប្រធាន អនុប្រធាន និងចៅក្រម គ្រប់តុលាការខេត្ត ក្រុង**

**លោក លោកស្រី ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមតុលាការខេត្ត ក្រុង**

**<u>កម្មវត្ថុ</u>:** អំពីការអនុវត្តន៍ច្បាប់ស្តីពីបទល្មើស បរិហារកេរ្តិ៍ ក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**<u>យោង</u>:** -មាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ

-ច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល

-ច្បាប់ស្តីពីសារព័ត៌មាន

-សេចក្តីថ្លែងការណ៍ជាសកលនូវសិទ្ធិនៃមនុស្ស

-ព្រឹត្តិកាសញ្ញាស្តីពីសិទ្ធិស៊ីវិល និង សិទ្ធិនយោបាយ

-សេចក្តីសម្រេចលេខ០៦៣/០០៥/២០០៤ កបធច ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤ របស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីបទ បរិហារកេរ្តិ៍ និងជេរប្រមាថ

កន្លងមកក្រសួងយុត្តិធម៌ និងតុលាការកំពូលបានកត់សម្គាល់ឃើញថា ការអនុវត្តន៍មាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលស្តីពីបទបរិហាកេរ្តិ៍ និងជេរប្រមាថបានជួបការលំបាកច្រើនដោយមូលហេតុថា ច្បាប់នេះបានតម្រូវឱ្យផ្តន្ទាទោសដាក់គុកពី០៨ ថ្ងៃទៅ០១ ឆ្នាំផង និងផ្តន្ទាទោសពិន័យជាប្រាក់ផង ឬផ្តន្ទាទោសតែទោសណាមួយក៏បាន ។

ហេតុដូច្នេះ ក្រសួងយុត្តិធម៌ និងតុលាការកំពូលសូមធ្វើការណែនាំដូចតទៅ៖

ក-ក្នុងករណីជនណាដែលបានប្រព្រឹត្តអំពើបរិហាកេរ្តិ៍ ឬអំពើជេរប្រមាថ មិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល តុលាការគប្បីអនុវត្តត្រឹមតែទោសពិន័យនោះបានហើយ ។ បើសិនជាមានបណ្តឹងសំណងរដ្ឋប្បវេណី គប្បីសម្រេចដោយថ្លឹងថ្លែងដល់ផលប៉ះពាល់នៃការខូចខាតនោះ ។

ខ-ក្នុងករណីជនណាដែលបានប្រព្រឹត្តិអំពើបរិហាកេរ្តិ៍ ឬជេរប្រមាថទៅលើបុគ្គលឯកជន បុបុគ្គលសាធារណៈ ហើយអាចបង្កលក្ខណៈឱ្យមានអស្ថេរភាព ដល់សន្តិសុខសាធារណៈសណ្តាប់ធ្នាប់សង្គម ឬធ្វើអោយមានភាពវឹកវរចលាចលដល់ស្ថេរភាពនយោបាយនិងសន្តិសុខជាតិ នោះត្រូវអនុវត្តតាមមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោក លោកស្រី ដែលជាចៅក្រម នឹងយកចិត្តទុកដាក់ក្នុងការអនុវត្តអោយបានល្អតាមការណែនាំខាងលើនេះ ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋលើប្រព័ន្ធតុលាការ និងច្បាប់របស់កម្ពុជា ។

ប្រធានតុលាការកំពូល

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
-ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា
-មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការ
-ឯកសារ-កាលប្បវត្តិ